# 10 សន្លឹកព័ត៌មានសំរាប់អ្នកដាំដំណាំលក់តាមទីផ្សារ
# ការធ្វើកសិកម្មតាមបែបធម្មជាតិ

ការធ្វើកសិកម្មតាមបែបធម្មជាតិគឺជាវិធីដាំដំណាំមួយដែលប្រើការដាក់បញ្ចូល និងរបៀបប្រើតាមបែបធម្មជាតិដែលកាត់បន្ថយផលប៉ះពាល់ដល់បរិដ្ឋាន។ ការធ្វើកសិកម្មតាមបែបធម្មជាតិក៏មានគោលបំណងបង្កើនសមាសធាតុធម្មជាតិនៅក្នុងដី(មមោក) ដែរ ដើម្បីឲ្យដំណាំទាំងអស់ទទួលគ្រឿងជីជាតិដែលកើតមានឡើងតាមធម្មជាតិ។

នេះគឺជាប្រព័ន្ធកសិកម្មមួយដែលមានភស្តុតាងច្បាស់លាស់ ដោយសារតែមានចំការធ្វើតាមបែបធម្មជាតិសំរាប់អាជីវកម្មចំនួនជាង១,៥០០នៅក្នុងប្រទេសអូស្ត្រាលី។ វាក៏ជាវិស័យចំណីអាហារដែលគេត្រូវការបំផុតនៅក្នុងពិភពលោក ហើយសេចក្តីត្រូវការនៅក្នុងប្រទេសអូស្ត្រាលីកំពុងលូតលាស់តាមកំរិត១០-២០ភាគរយក្នុងមួយឆ្នាំ។



NSW DPI, Virginia Brunton



NSW DPI, Virginia Brunton

## តើខ្ញុំត្រូវទាក់ទងជាមួយអ្នកណា ប្រសិនបើខ្ញុំមានការចាប់អារម្មណ៍?

ភ្នាក់ងារទំនាក់ទំនងក្រសួងឧស្សាហកម្មកែឆ្នៃវត្ថុធាតុដើម ការធ្វើកសិកម្មតាមបែបធម្មជាតិ រដ្ឋញូវសៅវែលៈ ទូរស័ព្ទលេខ 02 6951 2735

**សន្លឹកព័ត៌មានសំរាប់អ្នកដាំដំណាំលក់តាមទីផ្សារនេះ** គឺជាផ្នែកនៃលំដាប់ព័ត៌មានគ្រោងឡើងដើម្បីជួយដល់អ្នកដំណាំដែលមកពីសាវតាមិននិយាយភាសាអង់គ្លេស។ ដើម្បីទទួលយកព័ត៌មានច្រើនថែមទៀត សូមទាក់ទងជាមួយសាលាក្រុងក្នុងតំបន់របស់លោកអ្នក។ ប្រសិនបើលោកអ្នកត្រូវការអ្នកបកប្រែភាសា សូមទូរស័ព្ទ TIS លេខ 131 450។

គំរោងការនេះបានទទួលការផ្គត់ផ្គង់ពីរដ្ឋាភិបាលរដ្ឋញូវសៅវែល តាមរយៈមូលនិធិបរិដ្ឋានរបស់ខ្លួន (Environmental Trust)។

## តើសមាសធាតុធម្មជាតិនៅក្នុងដី(មមោក) ជាអ្វី?

សមាសធាតុធម្មជាតិនៅក្នុងដី(មមោក) គឺសមាសធាតុធម្មជាតិមួយមានពណ៌ត្នោត ឬខ្មៅ ដែលមានសារធាតុបន្លែ ឬសត្វពុកផុយរលួយ រហូតទាល់តែវាឈប់បន្តដំណើរការផ្លាស់ប្តូរ។ វាជួយបង្កើនទូវសមត្ថភាពរបស់ដីក្នុងការរក្សាទុកទឹក ហើយអាចរក្សាទុក និងបញ្ចេញគ្រឿងជីវជាតិសំរាប់រុក្ខជាតិ និងដីអស់រយៈពេលដ៏យូរលង់។

## តើការធ្វើកសិកម្មតាមបែបធម្មជាតិនឹងផ្តល់ប្រយោជន៍អ្វីខ្លះសំរាប់ខ្ញុំ?

ការធ្វើកសិកម្មតាមបែបធម្មជាតិអាចមានប្រយោជន៍ជាច្រើនសំរាប់កសិករៈ

**តម្លៃថ្លៃល្អៈ** ជាញឹកញាប់កសិករទទួលតម្លៃកាន់តែខ្ពស់សំរាប់ផលិតផលធម្មជាតិ។ នៅក្រុងស៊ីដនីយ (ឆ្នាំ២០០៣-០៤) គេបានទទួលតម្លៃប្រចាំឆ្នាំដូចតទៅនេះសំរាប់ផលិតផលធម្មជាតិៈ ផ្លែល្ពៅ៤១ភាគរយ ដំឡូង៣៨ភាគរយ ប៉េងប៉ោះ៤៦ភាគរយ ខ្ទឹមបារាំង៦១ភាគរយ ហ្ស៊ូហ្គីនី៩០ភាគរយ ផ្លែក្រូច២៣ភាគរយ ផ្លែប៉ោម២២ភាគរយ និងមើមការ៉ុត៦៩ភាគរយ។

**បង្កើននូវសេចក្តីត្រូវការរឹតកាន់តែច្រើនឡើងៈ** គ្រាសព្វថ្ងៃនេះអ្នកលក់ដុំ និងអ្នកលក់រាយកំពុងស្វែងរកផលិតចំណីអាហារធម្មជាតិបន្ថែមទៀត ហើយផលិតករនៅក្រុងស៊ីដនីយមានតែមួយចំនួនតូចប៉ុណ្ណោះ។

**មានលទ្ធភាពលក់នៅតាមទីផ្សារថ្មីៗៈ** អ្នកលក់ដុំឯកទេស (ដូចជា EcoFarms) និងអ្នកលក់រាយទាំងឡាយ (ដូចជា Macro Wholefoods) ផ្សារកសិករ និងភោជនីយដ្ឋានខ្លះកំពុងខិតខំជាខ្លាំងក្នុងការស្វែងរកផលិតផលធម្មជាតិ។

**បន្តការផ្គត់ផ្គង់សំរាប់ទីផ្សាដែលមានរួចមកហើយៈ** Coles និង Woolworths កំពុងពង្រីកយ៉ាងលឿននូវការលក់ចំណីអាហារ ធម្មជាតិជាច្រើនមុខរបស់ខ្លួនដែលមានរួចមកហើយ។

**មានសុខភាពកាន់តែប្រសើរៈ** គេមិនប្រើជាតិជីគីមីសិប្បនិម្មិត ថ្នាំសម្លាប់សត្វចង្រៃ និងថ្នាំសម្លាប់រុកជាតិតូចៗឥតប្រយោជន៍ឡើយ។

**បរិដ្ឋានៈ** ការគ្រប់គ្រងដីកាន់តែល្អប្រសើរឡើង និងការប្រើប្រាស់សារធាតុគីមីកាន់តែតិចទៅ បណ្តាលឲ្យមានការកែលំអគុណភាពទឹក និងដី។

**គុណភាពដីកាន់តែល្អឡើងៈ** ការអនុវត្តកសិកម្មតាមបែបធម្មជាតិ ធ្វើឲ្យកំរិតសមាសធាតុធម្មជាតិនៅក្នុងដី(មមោក) មានកាន់តែច្រើនឡើង។ ហេតុការណ៍នេះបណ្តាលឲ្យសមត្ថភាពផ្ទុកទឹកកាន់តែល្អ ជាតិទឹក pH កាន់តែមានស្ថេរភាព ហើយបង្កើនជីជាតិរបស់ដីសំរាប់រយៈពេលដ៏យូរផងដែរ។

## តើខ្ញុំត្រូវធ្វើការអ្វីខ្លះដើម្បីឲ្យមានការខុសផ្វែក?

ដើម្បីលក់ចំណីអាហារធម្មជាតិ លោកអ្នកនឹងត្រូវទទួលការបញ្ជាក់ជាផ្លូវការពីអង្គការមួយ ក្នុងចំណោមអង្គការប្រាំពីរដែលទទួលអាជ្ញាបណពីកិច្ចបំរើឃាត់ទុក និងត្រួតពិនិត្យអូស្ត្រាលី (AQIS)។ អង្គការទាំងនេះនឹងអាចជំរាបលោកអ្នកអំពីការអនុវត្តទាំងនេះ ដែលលោកអ្នកនឹងត្រូវផ្លាស់ប្តូរដើម្បីទទួលការបញ្ជាក់ជាផ្លូវការ។

ព័ត៌មានបន្ថែមទៀតអាចទទួលបានពីៈ http://www.dpi.nsw.gov.au/agriculture/farm/organic

ព័ត៌មានដែលចុះនៅក្នុងការចុះផ្សាយនេះសំអាងទៅលើចំណេះដឹង និងការដឹងយល់នៅចំពេលកំពុងសរសេរ (ខែវិច្ឆិកា ឆ្នាំ២០០៧)។ ទោះជាយ៉ាងណាក្តី ដោយព្រោះតែការចំរើនលើចំណេះដឹង អ្នកប្រើប្រាស់ត្រូវបានរំលឹកប្រាប់ពីសេចក្តីត្រូវការដើម្បីឲ្យបានប្រាកដថាព័ត៌មានដែលគេពឹងផ្អែកនោះគឺទាន់ពេលថ្មីៗ ហើយត្រូវឆែកមើលព័ត៌មានបច្ចុប្បន្នជាមួយភ្នាក់ងារសមស្របនៃក្រសួងឧស្សាហកម្មកែឆ្នៃវត្ថុធាតុដើម រដ្ឋញូវសៅវែល ឬជាមួយអ្នកប្រឹក្សាឯករាជ្យនៃអ្នកប្រើប្រាស់ព័ត៌មាននេះ។

NSW DEPARTMENT OF PRIMARY INDUSTRIES

NSW Environmental TRUST